ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយអគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីសិក្ខាសាលាផ្សព្វផ្សាយប្រព័ន្ធពន្ធដារកម្ពុជា

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារនឹងរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធពន្ធដារកម្ពុជាដល់អ្នកជាប់ពន្ធស្ថិតក្នុងរបបស្វ័យប្រកាសនៅខេត្តសៀមរាបជាពិសេស សណ្ឋាគារ ផ្ទះសំណាក់ អាផាតម៉ិន និងភោជនីយដ្ឋាន **នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១២:៣៥ នាទីរសៀល នៅសណ្ឋាគារ សូហ្វីតែលអង្គរភូគីត្រា ខេត្តសៀមរាប។**

សិក្ខាសាលានឹងប្រារព្ធឡើងក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយករង លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្តសៀមរាប និងមន្ត្រី នៃអគ្គនាយកដ្ឋានពន្ធដារ លោក-លោកស្រី តំណាងក្រុមហ៊ុនចំនួន ៤០០ នាក់។

ការរៀបចំឡើងនូវសិក្ខាសាលាស្តីពីប្រព័ន្ធពន្ធដារកម្ពុជាដល់អ្នកជាប់ពន្ធក្នុងគោលបំណងពង្រីកនូវការយល់ដឹងឲ្យបានទូលំទូលាយនូវរាល់បទប្បញ្ញត្តិស្តីពីសារពើពន្ធ និងពង្រឹងនូវការគោរពប្រតិបត្តិច្បាប់ ដែលជាកាតព្វកិច្ចខានមិនបានរបស់អ្នកជាប់ពន្ធ ក៏ដូចជារដ្ឋបាលសារពើពន្ធ។ តាមរយៈសិក្ខាសាលានេះ អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់ថា តំណាងក្រុមហ៊ុនទាំងអស់នឹងទទួលបានចំណេះដឹងថ្មីៗ បន្ថែមទៀត ដើម្បីជាទុនក្នុងការយកទៅអនុវត្តបានត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

សិក្ខាសាលានឹងផ្តោតលើការស្វែងយល់ពីប្រភេទពន្ធសំខាន់ៗ ដែលសហគ្រាសជាសណ្ឋាគារ ផ្ទះសំណាក់ អាផាតម៉ិន និងភោជនីយដ្ឋាន មានកាតព្វកិច្ចបង់ជូនរដ្ឋបាលសារពើពន្ធដែលរួមមាន អាករពិសេស អាករបំភ្លឺសាធារណៈ អាករស្នាក់នៅ អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់បៀវត្ស ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអបប្បរមា និងពន្ធលើប្រាក់ចំណេញ។ល។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់មេត្តាជ្រាបតាមការគួរ។

**អគ្គនាយកដ្ឋានពន្ធដារ**